# ព័ត៌មានថ្មីៗអំពីវ៉ាក់សាំងជំងឺគ្រុនផ្ដាសាយធំ ផ្លូវដង្ហើម និង COVID-19 សម្រាប់រដូវស្លឹកឈើជ្រុះ ឆ្នាំ 2023

អ្នកអាចមានសិទ្ធិចាក់វ៉ាក់សាំងចំនួន 3 នៅរដូវស្លឹកឈើជ្រុះនេះសម្រាប់ជំងឺគ្រុនផ្ដាសាយធំ ផ្លូវដង្ហើម និង COVID-19។



ចាក់វ៉ាក់សាំង COVID-19 ថ្មី ដើម្បីការពារប្រឆាំងនឹង COVID-19 បំប្លែងថ្មីៗ។ ការពារប្រឆាំងនឹងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងរោគសញ្ញា COVID រយៈពេលយូរ។



វ៉ាក់សាំងជំងឺគ្រុនផ្ដាសាយធំផ្ដល់នូវការការពារដល់គ្រប់គ្នាដែលមានអាយុ 6 ខែឡើងទៅសម្រាប់រដូវផ្ដាសាយធំដែលអាចបន្តដល់រដូវផ្ការីក។



មនុស្សពេញវ័យដែលមានអាយុ 60 ឆ្នាំឡើងទៅ និងគ្រប់គ្នាដែលមានផ្ទៃពោះចាប់ពី 24 ដល់ 36 សប្តាហ៍ គួរជជែកជាមួយវេជ្ជបណ្ឌិត ឬឱសថការី ដើម្បីដឹងថាតើត្រូវចាក់វ៉ាក់សាំងជំងឺផ្លូវដង្ហើមឬអត់។

Public Health
Seattle & King County

**kingcounty.gov/findaclinic**

ខែកញ្ញា ឆ្នាំ 2023



# COVID-19 មិនទាន់សាបសូន្យទេ

## កុំរង់ចាំអី។ ការពារខ្លួនអ្នក។ ចាក់វ៉ាក់សាំង COVID-19 ថ្មី ដោយឥតគិតប្រាក់ពីអ្នក!

វ៉ាក់សាំង COVID-19 ថ្មីមានផ្តល់ជូនដោយឥតគិតប្រាក់តាមរយៈ Bridge Access Program (កម្មវិធីតភ្ជាប់លទ្ធភាពទទួលបាន) សម្រាប់មនុស្សពេញវ័យដែលមានសិទ្ធិទាំងអស់ដែលមិនត្រូវបានធានារ៉ាប់រង ឬមានគម្រោងធានារ៉ាប់រងសុខភាពដែលមិនរ៉ាប់រងលើវ៉ាក់សាំងនេះ។

ចូលទៅកាន់ vaccines.gov ដើម្បីស្វែងរកការណាត់ជួបដែលនៅក្បែរអ្នក។ ស្វែងរកទីតាំងដែលផ្តល់វ៉ាក់សាំងពី "Bridge Access Program" ដោយរួមបញ្ចូលឱសថស្ថាន CVS និង Walgreens ជាច្រើន។

Public Health
Seattle & King County




# គ្លីនិកចាក់វ៉ាក់សាំង COVID-19 នៅ Public Health Kent

បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 28 ខែកញ្ញា ឆ្នាំ 2023

## បច្ចុប្បន្ននេះ យើងបានធ្វើបច្ចុប្បន្នភាពវ៉ាក់សាំង COVID-19 សម្រាប់៖

- មនុស្សពេញវ័យដែលមិនមានការធានារ៉ាប់រង និងមានការធានារ៉ាប់រងមិនគ្រប់គ្រាន់ដែលមានអាយុ 19 ឆ្នាំឡើងទៅ ដោយឥតគិតប្រាក់។
- មនុស្សពេញវ័យដែលមានការធានារ៉ាប់រងដែលមានអាយុ 19 ឆ្នាំឡើងទៅ (វ៉ាក់សាំង Pfizer តែប៉ុណ្ណោះ)។ សូមយកព័ត៌មានអំពីការធានារ៉ាប់រងរបស់អ្នកទៅតាមការណាត់ជួប។
- យើងកំពុងរង់ចាំការផ្គត់ផ្គង់វ៉ាក់សាំងសម្រាប់កុមារនៅឡើយ។

**ម៉ោង៖**

**អង្គារ – សៅរ៍ ម៉ោង 9:30 ព្រឹក – 12:30 ថ្ងៃត្រង់ និង 1:30 រសៀល – 6:00 យប់។**

លទ្ធភាពទទួលបានពីការទៅដោយផ្ទាល់មានដែនកំណត់ខ្លាំង។ យើងសូមណែនាំឱ្យធ្វើការណាត់ជួប។

កំណត់ពេលណាត់ជួប៖ kingcounty.gov/kentvaccine (ជាភាសាអង់គ្លេស) ឬហៅទូរសព្ទទៅលេខ 206-477-6950 រួចជ្រើសយកជម្រើស #4។ អ្នកអាចស្នើសុំជាភាសារបស់អ្នកបាន បើអ្នកត្រូវការអ្នកបកប្រែ។

ចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយធំដោយឥតគិតថ្លៃ បើអ្នកចាក់វ៉ាក់សាំង COVID-19។

ដើម្បីចាក់វ៉ាក់សាំង អ្នកមិនចាំបាច់ចុះឈ្មោះជាអ្នកជំងឺនៅ Kent Public Health ទេ។

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖** kingcounty.gov/vaccine។